**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ៦៥ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការអនុវត្តអាករលើតម្លៃបន្ថែមចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### មាត្រា១.- គោលបំណងនិងគោលដៅ

អនុក្រឹត្យនេះ កំណត់អំពីលក្ខខណ្ឌពិសេស និងដាក់ចេញនូវយន្តការអនុវត្តអាករលើតម្លៃបន្ថែមលើទំនិញឌីជីថល និងសេវាឌីជីថលដែលធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់ប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា និងធ្វើការផ្គត់ផ្គង់ដោយអ្នកជាប់ពន្ធអនិវាសនជនដែលមិនមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តស្របតាមមាត្រា៧៥ នៃច្បាប់ស្តីពីសារពើពន្ធ ។

### មាត្រា២.- វិសាលភាព

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថលតាមប្រព័ន្ធអេឡិចត្រូនិក ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលធ្វើឡើងដោយអ្នកផ្គត់ផ្គង់អនិវាសនជននៅក្រៅព្រះរាជាណាចក្រកម្ពុជាមកក្នុងព្រះរាជាណាចក្រកម្ពុជា។ ដោយឡែកចំពោះសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែមជាធរមាន។

### មាត្រា៣.- និយមន័យ

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យ ដូចខាងក្រោម÷

១. ពាក្យ "ការផ្គត់ផ្គង់ទំនិញ ឬសេវា ពីអាជីវកម្មទៅអាជីវកម្ម (Business to Business - B2B)" សំដៅដល់ការផ្គត់ផ្គង់ទំនិញ ឬសេវា ពីសហគ្រាសមួយទៅសហគ្រាសមួយទៀត។

២. ពាក្យ "ការផ្គត់ផ្គង់ទំនិញ ឬសេវា ពីអាជីវកម្មទៅអ្នកប្រើប្រាស់ (Business to Consumer - B2C)" សំដៅដល់ការផ្គត់ផ្គង់ទំនិញ ឬសេវា ពីសហគ្រាសទៅអ្នកប្រើប្រាស់។

៣. ពាក្យ "ទំនិញឌីជីថល" សំដៅដល់ទំនិញអរូបីដែលត្រូវបានបញ្ជាទិញ ផ្គត់ផ្គង់ និងបញ្ជូនទាំងស្រុងតាមប្រព័ន្ធអេឡិចត្រូនិក។

៤. ពាក្យ "សេវាឌីជីថល" សំដៅដល់សេវាដែលត្រូវបានធ្វើប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក។

៥. ពាក្យ "ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក" (Electronic Commerce) សំដៅដល់សកម្មភាពទិញ លក់ ជួល ផ្លាស់ប្តូរទំនិញ ឬសេវា ដោយរាប់បញ្ចូលទាំងសកម្មភាពពាណិជ្ជកម្ម និងរដ្ឋប្បវេណីតាមប្រព័ន្ធអេឡិចត្រូនិក។ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក រួមមានសកម្មភាព ឬប្រតិបត្តិការអាជីវកម្មដោយមិនកម្រិតត្រឹមតែទម្រង់ដូចមានក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

៦. ពាក្យ "វិធីគិតអាករជំនួស" (Reverse Charge) សំដៅដល់វិធីសាស្ត្រដែលបុគ្គលទទួលការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថលតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវគិតអាករលើតម្លៃបន្ថែមជំនួសបុគ្គលដែលផ្គត់ផ្គង់លើតម្លៃជាប់អាករ។

៧. ពាក្យ "អ្នកជាប់ពន្ធនិវាសនជន" សំដៅដល់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលបានចុះបញ្ជីតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ និងធ្វើការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថលតាមប្រព័ន្ធអេឡិចត្រូនិក ឬធ្វើសកម្មភាពអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៨. ពាក្យ "អ្នកជាប់ពន្ធអនិវាសនជន" សំដៅដល់បុគ្គលណាមួយដែលមិនមែនជាអ្នកជាប់ពន្ធនិវាសជនតាមចំណុចទី៧ នៃមាត្រានេះ ដែលធ្វើការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល តាមប្រព័ន្ធអេឡិចត្រូនិកពីក្រៅប្រទេសមកក្នុងព្រះរាជាណាចក្រកម្ពុជា។

៩. ពាក្យ "អាករ" សំដៅដល់ អាករលើតម្លៃបន្ថែម។

## ជំពូកទី ២
## កាតព្វកិច្ចសារពើពន្ធ

### មាត្រា៤.- ការចុះបញ្ជីពន្ធដារ

រាល់អ្នកជាប់ពន្ធអនិវាសនជនដែលមិនមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា ដែលធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវមានកាតព្វកិច្ចចុះបញ្ជីពន្ធដារដោយផ្អែកតាមចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការចុះបញ្ជីនេះត្រូវបានអនុវត្តសម្រាប់គោលដៅអាករលើតម្លៃបន្ថែមតែប៉ុណ្ណោះ។

### មាត្រា៥.- ការផ្គត់ផ្គង់ទំនិញ ឬសេវា ពីអាជីវកម្មទៅអ្នកប្រើប្រាស់

អ្នកជាប់ពន្ធអនិវាសនជនដែលបានផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមកអ្នកប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់អាករលើតម្លៃបន្ថែមមករដ្ឋបាលសារពើពន្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ ពីខែដែលបានទូទាត់។

### មាត្រា៦.- ការផ្គត់ផ្គង់ទំនិញ ឬសេវា ពីអាជីវកម្មទៅអាជីវកម្ម

អ្នកជាប់ពន្ធនិវាសនជនដែលទទួលការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីអ្នកជាប់ពន្ធអនិវាសនជន ត្រូវប្រមូលអាករតាមវិធីគិតអាករជំនួស (Reverse Charge) ហើយធ្វើការប្រកាសនិងបង់អាករលើតម្លៃបន្ថែមមករដ្ឋបាលសារពើពន្ធ តាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

### មាត្រា៧.- អាករលើធាតុចូល

អាករលើធាតុចូលដូចមានកំណត់ក្នុងមាត្រា៦ នៃអនុក្រឹត្យនេះ ត្រូវបានអនុញ្ញាតជាឥណទានអាករលើធាតុចូលដោយផ្អែកតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

### មាត្រា៨.- វិធាននិងនីតិវិធីលម្អិត

វិធាននិងនីតិវិធីលម្អិតនៃការអនុវត្តអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី ៣
## ទោសប្បញ្ញត្តិ

**មាត្រា៩.- ទោសទណ្ឌ**

អ្នកជាប់ពន្ធនិវាសនជន និងអនិវាសនជន ដែលមិនបានបំពេញកាតព្វកិច្ចតាមស្មារតីនៃអនុក្រឹត្យនេះ ត្រូវទទួលរងទោសទណ្ឌស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា១០.- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១១.- ការអនុវត្ត**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែមេសា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច

**ឧបសម្ព័ន្ធ**

**នៃអនុក្រឹត្យលេខ ស្ដីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះពាណិជ្ជកម្មតាមប្រព័ន្ធ**
**អេឡិចត្រូនិក ចុះថ្ងៃទី ខែ ឆ្នាំ២០២១**

## ទម្រង់នៃសកម្មភាព ឬប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងសេចក្ដីពន្យល់

១. ដំណើរការនៃការបញ្ជាទិញទំនិញរូបីតាមប្រព័ន្ធអេឡិចត្រូនិក (Electronic Order Processing of Tangible Products) ៖

អតិថិជនជ្រើសរើសទំនិញរូបីក្នុងបញ្ជីមុខទំនិញតាមអ៊ីនធឺណិត និងបញ្ជាទិញទំនិញទាំងនោះដោយផ្ទាល់តាមប្រព័ន្ធអេឡិចត្រូនិកពីអ្នកផ្គត់ផ្គង់ ហើយទំនិញរូបីត្រូវបានបញ្ជូនទៅអតិថិជនតាមមធ្យោបាយផ្សេងៗ។ ជាទូទៅ អតិថិជនមិនត្រូវបានតម្រូវឱ្យមានការគិតថ្លៃដាច់ដោយឡែកទៀតទេ សម្រាប់ការប្រើប្រាស់បញ្ជីមុខទំនិញតាមអ៊ីនធឺណិត។

២. ការបញ្ជាទិញនិងការទាញយក (Download) ទំនិញឌីជីថលតាមប្រព័ន្ធអេឡិចត្រូនិក (Electronic Ordering and Downloading of Digital Products)

អតិថិជនជ្រើសរើសសូហ្វវែរ (Software) ក្នុងបញ្ជីមុខទំនិញតាមអ៊ីនធឺណិត ឬផលិតផលឌីជីថលផ្សេងៗទៀត និងបញ្ជាទិញទំនិញទាំងនោះដោយផ្ទាល់តាមប្រព័ន្ធអេឡិចត្រូនិកពីអ្នកផ្គត់ផ្គង់ ហើយទំនិញឌីជីថលត្រូវបានទាញយកដាក់ក្នុងឧបករណ៍ផ្ទុកទិន្នន័យ (Hard Disk) របស់អតិថិជន ឬបញ្ជូនតាមមធ្យោបាយផ្សេងទៀត។ ជាទូទៅ អតិថិជនមិនត្រូវបានតម្រូវឱ្យមានការគិតថ្លៃដាច់ដោយឡែកទៀតទេ សម្រាប់ការប្រើប្រាស់បញ្ជីមុខទំនិញតាមអ៊ីនធឺណិត។

៣. ការបញ្ជាទិញនិងការទាញយកទំនិញឌីជីថលដែលមានសិទ្ធិអ្នកនិពន្ធតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់ប្រើប្រាស់ក្នុងគោលដៅពាណិជ្ជកម្ម (Electronic Ordering and Downloading of Digital Products for Purposes of Commercial Exploitation of the Copyright)

អតិថិជនជ្រើសរើសសូហ្វវែរ (Software) ក្នុងបញ្ជីមុខទំនិញតាមអ៊ីនធឺណិត ឬផលិតផលឌីជីថលផ្សេងៗទៀត និងបញ្ជាទិញទំនិញទាំងនោះដោយផ្ទាល់តាមប្រព័ន្ធអេឡិចត្រូនិកពីអ្នកផ្គត់ផ្គង់ ហើយទំនិញឌីជីថលត្រូវបានទាញយកដាក់ក្នុងឧបករណ៍ផ្ទុកទិន្នន័យ (Hard Disk) របស់អតិថិជន ឬបញ្ជូនតាមមធ្យោបាយផ្សេងទៀត។ ជាទូទៅ អតិថិជនមិនត្រូវបានតម្រូវឱ្យមានការគិតថ្លៃដាច់ដោយឡែកទៀតទេ សម្រាប់ការប្រើប្រាស់បញ្ជីមុខទំនិញតាមអ៊ីនធឺណិត។ អតិថិជនទទួលបានសិទ្ធិប្រើប្រាស់សិទ្ធិចម្លងទំនិញឌីជីថលក្នុងគោលដៅពាណិជ្ជកម្ម (ឧទាហរណ៍៖ អ្នកបោះពុម្ពសៀវភៅទទួលបានសិទ្ធិប្រើប្រាស់រូបភាព សម្រាប់យកទៅបោះពុម្ពលើក្របសៀវភៅ)។

៤. ការធ្វើបច្ចុប្បន្នភាព និងបន្ថែមមុខងារថ្មីៗទៅលើសូហ្វវែរ (Updates and Add-Ons)

អ្នកផ្គត់ផ្គង់សូហ្វវែរ (Software) ឬទំនិញឌីជីថលផ្សេងទៀត យល់ព្រមផ្ដល់ជូនអតិថិជននូវការធ្វើបច្ចុប្បន្នភាព (Updates) និងបន្ថែមមុខងារថ្មីៗ (Add-Ons) ទៅលើសូហ្វវែរ ដោយពុំមានកិច្ចព្រមព្រៀងដើម្បីផលិតកម្មវិធីធ្វើបច្ចុប្បន្នភាព ឬបន្ថែមមុខងារជាក់លាក់ណាមួយសម្រាប់ឱ្យអតិថិជននោះទេ។ អតិថិជនពុំមានសិទ្ធិប្រើប្រាស់ ឬធ្វើអាជីវកម្មនូវកម្មសិទ្ធិបញ្ញាលើផលិតផលឌីជីថល ឬបន្ថែមមុខងារថ្មីៗ ក្នុងគោលដៅពាណិជ្ជកម្មនោះទេ។

៥. **អាជ្ញាបណ្ណប្រើប្រាស់សូហ្វវែរមានកាលកំណត់ និងព័ត៌មានឌីជីថលផ្សេងៗ (Limited Duration Software and Other Digital Information Licenses)**

អតិថិជនទទួលបាននូវសិទ្ធិក្នុងការប្រើសូហ្វវែរ (Software) ឬផលិតផលឌីជីថលផ្សេងទៀត សម្រាប់រយៈពេលកំណត់មួយ ដែលមានរយៈពេលតិចជាងអាយុកាលរបស់ផលិតផលនោះ។ ផលិតផលនោះអាចទាញយកតាមប្រព័ន្ធអេឡិចត្រូនិក ឬតាមរយៈមធ្យោបាយផ្សេងៗ ដូចជាស៊ីឌី (CD) ជាដើម។ គ្រប់ផលិតផលឌីជីថល ត្រូវបានលុបចោល ឬមិនអាចប្រើបាននៅពេលផុតកំណត់នៃអាជ្ញាបណ្ណ។

៦. **សិទ្ធិប្រើប្រាស់តែមួយដងនូវសូហ្វវែរ ឬផលិតផលឌីជីថលផ្សេងៗ (Single-Use Software or Other Digital Product)**

អតិថិជនទទួលបាននូវសិទ្ធិតែមួយដងក្នុងការប្រើសូហ្វវែរ (Software) ឬផលិតផលឌីជីថលផ្សេងទៀត ដែលផលិតផលទាំងនោះអាចទាញយក ឬប្រើប្រាស់ពីចម្ងាយ (ឧទាហរណ៍÷ ការប្រើសូហ្វវែរដែលត្រូវបានរក្សាទុកដោយម៉ាស៊ីនមេពីចម្ងាយ)។ អតិថិជនមិនទទួលបានសិទ្ធិចម្លងបន្តលើផលិតផលឌីជីថលទាំងនោះ លើសពីលក្ខខណ្ឌប្រើប្រាស់ដែលបានកំណត់។

៧. **ការផ្គត់ផ្គង់សេវាបង្ហោះកម្មវិធីសូហ្វវែរ-អាជ្ញាបណ្ណដាច់ដោយឡែកពីគ្នា (Application Hosting-Separate License)**

អតិថិជនម្នាក់មានអាជ្ញាបណ្ណអចិន្ត្រៃយ៍សម្រាប់ការប្រើកម្មវិធីសូហ្វវែរមួយ។ អតិថិជនត្រូវចុះកិច្ចសន្យាជាមួយក្រុមហ៊ុនផ្តល់សេវា ដើម្បីដំឡើងកម្មវិធីនោះនៅលើម៉ាស៊ីនមេដែលគ្រប់គ្រងដោយក្រុមហ៊ុនផ្តល់សេវា។ ក្រុមហ៊ុនផ្តល់សេវាបង្ហោះកម្មវិធីសូហ្វវែរជាអ្នកគាំទ្របច្ចេកទេស និងការពារភាពមិនដំណើរការនៃប្រព័ន្ធរបស់អ្នកផ្តល់សេវា។ អតិថិជនអាចចូល, ប្រតិបត្តិ, និងបញ្ជាលើកម្មវិធីសូហ្វវែរពីចម្ងាយ។ កម្មវិធីនេះជាប្រតិបត្តិការលើកុំព្យូទ័ររបស់អតិថិជន បន្ទាប់ពីបានទាញយកទៅក្នុងអង្គចងចាំ (RAM) ឬពីម៉ាស៊ីនមេរបស់ក្រុមហ៊ុនផ្តល់សេវា។ ការរៀបចំប្រភេទនេះអាចអនុវត្ត ឧទាហរណ៍÷ ការផ្គត់ផ្គង់ហិរញ្ញវត្ថុ, ការគ្រប់គ្រងសារពើភណ្ឌ, ការគ្រប់គ្រងធនធានមនុស្ស ឬការគ្រប់គ្រងធនធានសហគ្រាស នៃកម្មវិធីសូហ្វវែរ។

៨. **ការផ្គត់ផ្គង់សេវាបង្ហោះកម្មវិធីសូហ្វវែរ-កិច្ចសន្យាជាកញ្ចប់ (Application Hosting-Bundled Contract)**

អតិថិជនត្រូវចុះកិច្ចសន្យាជាមួយក្រុមហ៊ុនផ្តល់សេវា ដើម្បីប្រើប្រាស់កម្មវិធីផ្សេងៗនៅលើម៉ាស៊ីនមេដែលគ្រប់គ្រងដោយក្រុមហ៊ុនផ្តល់សេវាដោយផ្ទាល់។ ក្រុមហ៊ុនផ្តល់សេវាបង្ហោះកម្មវិធីសូហ្វវែរជាអ្នកគាំទ្របច្ចេកទេស និងការពារភាពមិនដំណើរការនៃប្រព័ន្ធរបស់អ្នកផ្តល់សេវាទាំងហាដវែរ(Hardware) និងសូហ្វវែរ (Software)។ អតិថិជនអាចចូល, ប្រតិបត្តិ, និងបញ្ជាលើកម្មវិធីសូហ្វវែរពីចម្ងាយ។ អតិថិជនអាចប្រើប្រាស់កម្មវិធីដោយប្រតិបត្តិលើកុំព្យូទ័ររបស់ខ្លួន បន្ទាប់ពីបានទាញយកដាក់ក្នុងអង្គចងចាំ (RAM) ឬប្រើនៅលើម៉ាស៊ីនមេរបស់ក្រុមហ៊ុនផ្តល់សេវា។ កិច្ចសន្យានេះអាចបន្តជារៀងរាល់ឆ្នាំជាមួយកម្រៃសេវាបន្ថែម។

៩. **អ្នកផ្តល់សេវាប្រើប្រាស់កម្មវិធីសូហ្វវែរតាមអនឡាញ (Application Service Provider-ASP)**

អ្នកផ្តល់សេវាប្រើប្រាស់កម្មវិធីសូហ្វវែរតាមអនឡាញ ត្រូវមានអាជ្ញាបណ្ណសម្រាប់ផ្តល់សេវាប្រើប្រាស់កម្មវិធីសូហ្វវែរដល់អតិថិជនរបស់ខ្លួន។ អ្នកផ្តល់សេវាអាចអនុញ្ញាតឱ្យអតិថិជនចូលប្រើនូវកម្មវិធីសូហ្វវែរតាមរយៈកុំព្យូទ័រមេរបស់ខ្លួន។ កម្មវិធីសូហ្វវែរត្រូវបានដំណើរការដោយស្វ័យប្រវត្តិនូវមុខងារអាជីវកម្មរបស់អតិថិជន។ ឧទាហរណ៍÷ កម្មវិធីសូហ្វវែរ អាចធ្វើស្វ័យប្រវត្តិកម្មស្វែងរកប្រភព, បញ្ជាទិញ, ទូទាត់ប្រាក់, និងបញ្ជូនទំនិញឬ

សេវា ដែលត្រូវបានប្រើប្រាស់ក្នុងអាជីវកម្មរបស់អតិថិជន។ អ្នកផ្តល់សេវាប្រើប្រាស់កម្មវិធីសូហ្វវែរតាមអនឡាញ មិនមែនជាអ្នកផ្គត់ផ្គង់ទំនិញឬសេវាកម្មទេ គឺគ្រាន់តែជាការផ្តល់ជូនអតិថិជននូវមធ្យោបាយស្វ័យប្រវត្តិកម្មភ្ជាប់ទៅភាគីទីបីដែលជាអ្នកផ្គត់ផ្គង់ទំនិញនិងសេវានោះ។ អតិថិជនពុំមានសិទ្ធិថតចម្លងកម្មវិធីសូហ្វវែរ ឬប្រើប្រាស់សូហ្វវែរលើសពីការអនុញ្ញាតរបស់អ្នកផ្តល់សេវាប្រើប្រាស់កម្មវិធីសូហ្វវែរតាមអនឡាញ។

**១០. កម្រៃលើអាជ្ញាបណ្ណដែលអ្នកផ្តល់សេវាប្រើប្រាស់កម្មវិធីសូហ្វវែរតាមអនឡាញត្រូវបង់ (ASP License Fees)**

អ្នកផ្តល់សេវាប្រើប្រាស់កម្មវិធីសូហ្វវែរតាមអនឡាញ ត្រូវទូទាត់ទៅឱ្យអ្នកផ្គត់ផ្គង់កម្មវិធីសូហ្វវែរនូវកម្រៃអាជ្ញាបណ្ណដោយគិតជាភាគរយនៃចំណូលដែលប្រមូលបានពីអតិថិជនតាមកិច្ចសន្យា។

**១១. សេវាបង្ហោះគេហទំព័រ (Website Hosting)**

អ្នកផ្តល់សេវាបង្ហោះគេហទំព័រ ផ្តល់ទំហំផ្ទុកទិន្នន័យនៅលើម៉ាស៊ីនមេរបស់ខ្លួនសម្រាប់បង្ហោះគេហទំព័រ។ អ្នកផ្តល់សេវាបង្ហោះគេហទំព័រមិនមានសិទ្ធិលើកម្មសិទ្ធិបញ្ញានៃមាតិកាគេហទំព័រដែលអ្នកអភិវឌ្ឍកម្មវិធីបានបង្កើតឡើយ។ ម្ចាស់គេហទំព័រមានសិទ្ធិផ្លាស់ប្តូរ កែប្រែគេហទំព័រ រួមទាំងការកែប្រែមាតិកានៃគេហទំព័រ។ អ្នកផ្តល់សេវាបង្ហោះគេហទំព័រ ទទួលបានកម្រៃតាមរយៈការចូលប្រើប្រាស់របស់អតិថិជន។

**១២. សេវាថែទាំលើកម្មវិធីសូហ្វវែរ (Software Maintenance)**

កិច្ចសន្យាថែទាំកម្មវិធីសូហ្វវែរជាកញ្ចប់ រួមមាន ការធ្វើបច្ចុប្បន្នភាពនិងការគាំទ្របច្ចេកទេស។ កម្រៃប្រចាំឆ្នាំសម្រាប់កិច្ចសន្យានេះត្រូវបានរួមបញ្ចូលទាំងការធ្វើបច្ចុប្បន្នភាពនិងការគាំទ្របច្ចេកទេស។ ករណីភាគច្រើន កម្មវត្ថុចម្បងនៃកិច្ចសន្យាគឺផ្តោតលើការផ្តល់សេវាធ្វើបច្ចុប្បន្នភាពកម្មវិធីសូហ្វវែរ។

**១៣. សេវាផ្ទុកទិន្នន័យ (Data Warehousing)**

អតិថិជនអាចផ្ទុកទិន្នន័យកុំព្យូទ័ររបស់ខ្លួននៅលើម៉ាស៊ីនមេដែលគ្រប់គ្រង និងបញ្ជាដោយអ្នកផ្តល់សេវាផ្ទុកទិន្នន័យ។ អតិថិជនអាចចូលប្រើប្រាស់, ផ្ទុក, ទាញយក និងរៀបចំទិន្នន័យពីចម្ងាយ ដោយចាំបាច់មានអាជ្ញាបណ្ណពីអ្នកផ្តល់សេវា។ ប៉ុន្តែអតិថិជនត្រូវមានកិច្ចសន្យាអំពីការប្រើប្រាស់នេះជាមួយអ្នកផ្តល់សេវា។

**១៤. សេវាគាំទ្របច្ចេកទេសតាមបណ្តាញកុំព្យូទ័រ (Customer Support over a Computer Network)**

អ្នកផ្តល់សេវានេះ ផ្តល់ឱ្យអតិថិជននូវការគាំទ្រខាងបច្ចេកទេសតាមបណ្តាញអ៊ីនធឺណិត រួមទាំងការប្រឹក្សាយោបល់ដើម្បីដំឡើងកម្មវិធីសូហ្វវែរ និងការផ្តល់ព័ត៌មានដើម្បីដោះស្រាយបញ្ហាបច្ចេកទេស។ សេវាគាំទ្រនេះអាចផ្តល់ជូនតាមរយៈឯកសារបច្ចេកទេសអនឡាញ និងទំនាក់ទំនងជាមួយអ្នកបច្ចេកទេសតាមរយៈអ៊ីម៉ែល ឬទូរសព្ទ។

**១៥. ការទាញយកទិន្នន័យ (Data Retrieval)**

អ្នកផ្តល់សេវានេះ បង្កើតឃ្លាំងផ្ទុកនូវរាល់ព័ត៌មានផ្សេងៗសម្រាប់ឱ្យអតិថិជនធ្វើការស្វែងរកនិងទាញយក។ សារប្រយោជន៍ចម្បងសម្រាប់អតិថិជន គឺលទ្ធភាពក្នុងការស្វែងរក និងស្រង់យកទិន្នន័យជាក់លាក់ណាមួយក្នុងចំណោមទិន្នន័យជាច្រើនទៀតដែលអាចទាញយកបាន។

**១៦. ការផ្តល់ទិន្នន័យផ្តាច់មុខ ឬទិន្នន័យមានតម្លៃខ្ពស់ដទៃទៀត (Delivery of Exclusive or Other High-Value Data)**

អ្នកផ្តល់សេវានេះ រៀបចំប្រមូលទិន្នន័យនិងធ្វើការវិភាគលើទិន្នន័យទាំងនោះដើម្បីធ្វើជារបាយការណ៍ឬទិន្នន័យបំប្លែងមានលក្ខណៈពិសេសណាមួយសម្រាប់ផ្តល់ជូនអតិថិជន (ឧទាហរណ៍÷ របាយការណ៍ទាក់ទិនទៅនឹងវិស័យឧស្សាហកម្មឬវិនិយោគ)។ អតិថិជនអាចធ្វើការបង់ប្រាក់ដើម្បីទាញយកនូវទិន្នន័យឬរបាយការណ៍ទាំងនោះតាមរយៈអនឡាញ។

**១៧. ការផ្សាយពាណិជ្ជកម្ម (Advertising)**

អ្នកចង់ផ្សព្វផ្សាយពាណិជ្ជកម្មអាចធ្វើការបង់ប្រាក់ ដើម្បីឱ្យសាធារណជនអាចមើលឃើញនូវផ្ទាំងផ្សព្វផ្សាយរបស់ខ្លួនតាមរយៈគេហទំព័រណាមួយ។ អត្រាតម្លៃសម្រាប់ការផ្សព្វផ្សាយនេះ ត្រូវបានគិតថ្លៃជាចំនួនដងនៃការបង្ហាញ ឬចំនួនដងនៃការចុចមើលផ្ទាំងផ្សព្វផ្សាយនោះ (ឧទាហរណ៍÷ គិតតម្លៃរៀងរាល់ការបង្ហាញមួយពាន់ដងម្តង ឬចុចមើលម្តងគិតប្រាក់ម្តង)។

**១៨. សេវាពិគ្រោះយោបល់តាមប្រព័ន្ធអេឡិចត្រូនិក (Electronic Access to Professional Advice)**

អ្នកប្រឹក្សាយោបល់, មេធាវី, វេជ្ជបណ្ឌិត និងអ្នកជំនាញអាជីពផ្សេងទៀត អាចផ្តល់សេវាពិគ្រោះយោបល់ជូនអតិថិជនតាមរយៈអ៊ីម៉ែល, ការពិភាក្សាតាមរយៈវីដេអូ (Video Conferencing) ឬតាមរយៈការទាក់ទងពីចម្ងាយផ្សេងទៀត។

**១៩. ព័ត៌មានបច្ចេកទេស (Technical Information)**

ព័ត៌មានបច្ចេកទេសសម្ងាត់ដែលទាក់ទិនទៅនឹងផលិតផល ឬកិច្ចដំណើរការផលិតត្រូវបានផ្តល់ជូនអតិថិជន (ឧទាហរណ៍÷ រូបមន្ត និងដ្យាក្រាមសម្ងាត់នៃដំណើរការផលិត)។

**២០. ការបញ្ជូនព័ត៌មាន (Information Delivery)**

អ្នកផ្តល់សេវាបញ្ជូនទិន្នន័យតាមប្រព័ន្ធអេឡិចត្រូនិកទៅអតិថិជន តាមកាលកំណត់ស្របតាមការជ្រើសរើសផ្ទាល់ខ្លួន។ សារប្រយោជន៍ចម្បងសម្រាប់អតិថិជនគឺភាពងាយស្រួលនៃការទទួលបាននូវព័ត៌មានទូលំទូលាយ តាមកញ្ចប់សេវាកម្មដែលខ្លួនបានជ្រើសរើស។

**២១. ការចូលទៅគេហទំព័រមានលក្ខណៈអន្តរសកម្ម (Access to an Interactive Website)**

អ្នកផ្តល់សេវាជូនដល់អតិថិជននូវគេហទំព័រដែលមានលក្ខណៈជាមាតិកាឌីជីថល រួមបញ្ចូលនូវព័ត៌មាន, តន្ត្រី, វីដេអូ, ល្បែងកម្សាន្ត និងសកម្មភាពផ្សេងៗ។ អតិថិជនបង់នូវកម្រៃកំណត់ណាមួយដើម្បីចូលប្រើប្រាស់សេវាកម្មនោះតាមកាលកំណត់ដែលបានជ្រើសរើស។

**២២. ផ្សារលក់ទំនិញតាមប្រព័ន្ធអ៊ីនធឺណិត (Online Shopping Portals)**

ប្រតិបត្តិករគេហទំព័របង្ហោះនូវបញ្ជីមុខទំនិញ តាមប្រព័ន្ធអេឡិចត្រូនិករបស់ពាណិជ្ជករជាច្រើនផ្សេងគ្នានៅលើម៉ាស៊ីនកុំព្យូទ័រមេរបស់ប្រតិបត្តិករនោះ។ អ្នកទិញអាចប្រើប្រាស់គេហទំព័រដើម្បីជ្រើសរើសផលិតផលពីបញ្ជីមុខទំនិញទាំងនោះនិងធ្វើការបញ្ជាទិញតាមអ៊ីនធឺណិត។ ប្រតិបត្តិករគេហទំព័រមិនមានទំនាក់ទំនងកិច្ចសន្យាជាមួយនឹងអ្នកទិញទំនិញទេ។ ប្រតិបត្តិករគេហទំព័រគ្រាន់តែបញ្ជូនការបញ្ជាទិញទៅឱ្យពាណិជ្ជករដែលជាអ្នកទទួលខុសត្រូវក្នុងការទទួលសំណើ និងបំពេញកាតព្វកិច្ចតាមការបញ្ជាទិញផ្សេងៗ។ ពាណិជ្ជករបង់ប្រាក់កម្រៃជើងសាទៅតាមបរិមាណនៃការបញ្ជាទិញ។

**២៣. ការដេញថ្លៃតាមប្រព័ន្ធអ៊ីនធឺណិត (Online Auctions)**

អ្នកផ្ដល់សេវាបង្ហោះមុខទំនិញជាច្រើនសម្រាប់ការទិញដោយដេញថ្លៃ។ អ្នកទិញទំនិញអាចទិញដោយផ្ទាល់ពីម្ចាស់ដើមដោយមិនមែនទិញពីអ្នកផ្ដល់សេវាកម្មបង្ហោះមុខទំនិញទេ។ អ្នកលក់បង់ថ្លៃសេវាដល់អ្នកផ្ដល់សេវាបង្ហោះមុខទំនិញដោយគិតជាមួយភាគរយនៃតម្លៃទំនិញឬតម្លៃថេរណាមួយ។

**២៤. កម្មវិធីណែនាំបន្តការលក់ទំនិញ និងសេវា (Sales Referral Programs)**

អ្នកលក់ផលិតផលតាមប្រព័ន្ធអ៊ីនធឺណិត បង់កម្រៃជើងសាទៅឱ្យប្រតិបត្តិករគេហទំព័រដែលបានជួយណែនាំបន្តទៅអតិថិជន ដោយប្រតិបត្តិករគេហទំព័របង្ហោះផលិតផលនោះនៅលើគេហទំព័ររបស់ខ្លួន។ ប្រសិនបើអ្នកប្រើប្រាស់ចុចលើតំណភ្ជាប់ផលិតផលណាមួយក្នុងចំណោមផលិតផលទាំងនោះ អ្នកប្រើប្រាស់នឹងបានចូលទៅកាន់គេហទំព័ររបស់អ្នកលក់ផលិតផលដើម្បីធ្វើការបញ្ជាទិញ។ អ្នកលក់ផលិតផលអាចកំណត់អត្តសញ្ញាណប្រភពតំណភ្ជាប់នៃការណែនាំការលក់ដើម្បីធ្វើការបង់នូវកម្រៃជើងសារជូនប្រតិបត្តិករគេហទំព័រ ប្រសិនបើអ្នកប្រើប្រាស់ទិញនូវផលិតផលនោះ។

**២៥. ប្រតិបត្តិការទិញមាតិកាព័ត៌មាន (Content Acquisition Transactions)**

ប្រតិបត្តិករគេហទំព័រធ្វើការបង់ប្រាក់កម្រៃជូនផលិតករដែលបានផលិតមាតិកាផ្សេងៗ ដូចជា អត្ថបទព័ត៌មាន ការជូនដំណឹង ដែលបានបង្ហោះនៅលើគេហទំព័ររបស់ខ្លួនក្នុងគោលបំណងទាក់ទាញអ្នកប្រើប្រាស់ឱ្យចូលប្រើគេហទំព័រនោះ។ ប្រតិបត្តិករគេហទំព័រអាចជួលផលិតករ ដើម្បីបង្កើតនូវមាតិកាព័ត៌មានជាក់លាក់ណាមួយសម្រាប់គេហទំព័ររបស់ខ្លួន។

**២៦. ការផ្សព្វផ្សាយផលិតផលសោតទស្សន៍តាមរយៈគេហទំព័រ [Streamed (Real Time) Web Based Broadcasting]**

អ្នកប្រើប្រាស់ចូលប្រើបណ្ដុំមាតិកានៃផលិតផលសោតទស្សន៍ដែលមានការរក្សាសិទ្ធិ។ ប្រតិបត្តិករផ្សព្វផ្សាយបានទទួលប្រាក់ចំណូលពីការជាវប្រចាំ ឬតាមរយៈការផ្សព្វផ្សាយពាណិជ្ជកម្ម។

**២៧. កម្រៃសេវាផ្សាយមាតិកាព័ត៌មាន (Carriage Fees)**

អ្នកផលិតមាតិកាបង់ប្រាក់កម្រៃសេវាជូនប្រតិបត្តិករគេហទំព័រ ដើម្បីអាចបង្ហាញនូវមាតិកាព័ត៌មានរបស់ខ្លួននៅលើគេហទំព័ររបស់ប្រតិបត្តិករ។

**២៨. ការចុះឈ្មោះប្រើប្រាស់ឬទាញយកផលិតផលឌីជីថលតាមគេហទំព័រ (Subscription to a Website Allowing the Downloading of Digital Products)**

អ្នកផ្ដល់សេវាផ្គត់ផ្គង់នូវផលិតផលឌីជីថល ផ្ដល់នូវសិទ្ធិប្រើប្រាស់ឬទាញយកផលិតផលឌីជីថលដែលមានការរក្សាសិទ្ធិជូនអតិថិជនដែលបានចុះឈ្មោះតាមគេហទំព័ររបស់ខ្លួន។ អតិថិជនបង់ប្រាក់កម្រៃក្នុងរយៈពេលកំណត់ណាមួយដើម្បីចូលប្រើប្រាស់គេហទំព័រនោះ។ សារប្រយោជន៍ចម្បងរបស់អ្នកប្រើប្រាស់ គឺមានលទ្ធភាពអាចទាញយកនូវផលិតផលឌីជីថលទាំងនោះ។